អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ២០១៣

# សេចក្តីប្រកាសព័ត៌មាន
# អង្គជំនុំជម្រះសាលាដំបូងចង្អុលបង្ហាញពីគម្រោងផែនការថ្ងៃខាងមុខសម្រាប់សំណុំរឿង ០០២/០២

នៅថ្ងៃនេះ អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានចេញអនុស្សរណៈមួយ ដោយបានជូនដំណឹងដល់ភាគីទាំងអស់នៃសំណុំរឿង ០០២ អំពីដំណាក់កាលបន្ទាប់មកទៀតសម្រាប់ការជំនុំ-ជម្រះនៅក្នុងដំណាក់កាលទីពីរនេះ។ អនុស្សរណៈ ដោយមានភ្ជាប់ជាមួយនូវផែនការការងារដែលបានគូសបញ្ជាក់ពីដំណាក់កាលសំខាន់ៗ និងសកម្មភាពចាំបាច់មួយចំនួន មុនពេលចាប់ផ្តើមសវនាការលើអង្គសេចក្តីនៅក្នុងសំណុំរឿង ០០២/០២ នោះ គឺត្រូវបានធ្វើឡើងភ្លាមៗបន្ទាប់ពីមានសេចក្តីសម្រេចរបស់ប្រធានអង្គជំនុំជម្រះសាលាដំបូងកាលពីសប្តាហ៍មុន ដែលមិនស្នើឲ្យបង្កើតក្រុមប្រឹក្សាជំនុំជម្រះទីពីរដើម្បីជំនុំជម្រះក្នុងដំណាក់កាលទីពីរនោះទេ។

នៅក្នុងអនុស្សរណៈរបស់ខ្លួន អង្គជំនុំជម្រះសាលាដំបូងបានចង្អុលបង្ហាញនូវបញ្ហាមួយចំនួន ដែលតម្រូវឲ្យមានដំណោះស្រាយជាមុន មុនពេលចាប់ផ្តើមសវនាការដេញដោលលើភ័ស្តុតាង។ បញ្ហាទាំងនោះរួមមាន វិសាលភាពនៃការជំនុំជម្រះ រួមទាំងអង្គហេតុនិងបទចោទនានាដែលមិនត្រូវបានរួមបញ្ចូលនៅក្នុងសំណុំរឿង ០០២/០២ ការវាយតម្លៃទៅលើសម្បទារបស់ជនជាប់ចោទ ការដាក់បញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណី ដែលភាគីមានបំណងស្តាប់សក្ខីកម្មនៅពេលសវនាការ ការដាក់បញ្ជីឯកសារដែលពាក់ព័ន្ធ និងការកំណត់នូវបញ្ហាអញ្ញត្រកម្មនានាដែលនៅសេសសល់ ។

ជាជំហានដំបូង អង្គជំនុំជម្រះសាលាដំបូងបានណែនាំដល់ភាគីឲ្យដាក់នូវសារណាស្តីពីបញ្ហាសម្បទារបស់ជនជាប់ចោទ យ៉ាងយូរបំផុតត្រឹមថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០១៤ និងសារណាស្តីពីវិសាលភាពនៃការជំនុំជម្រះយ៉ាងយូរបំផុតត្រឹមថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៤។ អង្គជំនុំជម្រះក៏បានណែនាំផងដែរ ដល់ក្រុមមេធាវី

ការពារក្ដីលោក ខៀវ សំផន ឲ្យដាក់សារណាដើម្បីគាំទ្រដល់អំណះអំណាងរបស់ខ្លួនដែលថា សំណុំរឿង ០០២/០១ គួរតែត្រូវបានសម្រេចជាស្ថាពរសិន ដែលរួមទាំងដំណើរការនីតិវិធីប្ដឹងសាទុក្ខ ប្រសិនបើមានមុនពេលចាប់ផ្ដើមសវនាការដេញដោលលើភ័ស្ដុតាងនៅក្នុងសំណុំរឿង ០០២/០២។ ដើម្បីពន្លឿនការដោះស្រាយលើបញ្ហាទាំងអស់នេះ អង្គជំនុំជម្រះបានប្រកាសពីចេតនារបស់ខ្លួន ក្នុងការបើកសវនាការស្ដាប់ទឡ្ហីករណ៍ផ្ទាល់មាត់របស់ភាគីនៅថ្ងៃទី ១១ ខែ កុម្ភៈ ឆ្នាំ ២០១៤ ជំនួសឲ្យការដាក់ចម្លើយតបជាលាយលក្ខណ៍អក្សរ។

ក្នុងសំណុំរឿង ០០២/០២ នួន ជា និង ខៀវ សំផន ប្រឈមនឹងការចោទប្រកាន់ពីឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការរំលោភបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ ១៩៤៩។ ការជំនុំជម្រះដំណាក់កាលទីមួយប្រឆាំងនឹងជនជាប់ចោទ ត្រូវបានបញ្ចប់ដោយការធ្វើសេចក្ដីសន្និដ្ឋានបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងខែ តុលា ឆ្នាំ ២០១៣ ហើយសាលក្រមលើការជំនុំជម្រះដំណាក់កាលទីមួយនេះ គ្រោងនឹងចេញនៅក្នុងអំឡុងត្រីមាសទីពីរ ក្នុងឆ្នាំ ២០១៤ ខាងមុខនេះ ។

អនុស្សរណៈទាំងស្រុងមាននៅក្នុងគេហទំព័ររបស់អ.វ.ត.ក៖ http://www.eccc.gov.kh/document/court/28449

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖**


លោក Lars Olsen
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរស័ព្ទដៃ៖ +៨៥៥ (០) ១២ ៤៨៨ ០២៣
ទូរស័ព្ទលើតុ៖ +៨៥៥ (០) ២៣ ៨៦១ ៦៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ៖ +៨៥៥ (០) ១២ ៤៨៨ ១៥៦
ទូរស័ព្ទលើតុ៖ +៨៥៥ (០) ២៣ ៨៦១ ៥៦៤
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh